កិច្ចបញ្ចុះទូក ឬទម្លាក់បង្គងនៅភូមិកំពង់ឈើទាល

ទូកខ្មែរ មានច្រើនប្រភេទណាស់អាស្រ័យទៅតាមការប្រើប្រាស់ និងបរិបទរស់នៅប្រចាំថ្ងៃ។ ក្នុងនោះ ទូកង ជាទូកប្រណាំង (ទូកអុំ និងទូកចែវ) ដែលគេនិយមប្រើប្រាស់ក្នុងឱកាសពិធីបុណ្យអុំទូក កឋិនទាន ឬចេញវស្សាជាដើម។ ក្រៅអំពីការប្រើប្រាស់សម្រាប់ប្រកួតប្រជែង ទូកងបានបង្កប់នូវបច្ចេកទេសផលិត សាមគ្គីភាព ប្រវត្តិសាស្ត្រ និងប្រភេទឈើធ្វើទូក។ ម្ល៉ោះហើយទើបមានពាក្យស្លោកមួយពោលថា **"គគីរនឹងទឹក ធ្នឹកនឹងដី សុក្រំហាលថ្ងៃ ស្រឡៅក្នុងម្ជុះ"**។ មនុស្សខ្មែរមានជំនឿថា គ្រប់ទូកងទាំងនោះមានអមនុស្សថែរក្សា ឬសណ្ឋិតនៅ។ ដូច្នេះហើយទើបគេតែងប្រារព្ធកិច្ចផ្សេងៗដូចជា កិច្ចសែនព្រះពិស្ណុការធ្វើទូក កិច្ចសែនពោងទូក កិច្ចបំពាក់ក្បែកទូក កិច្ចលេងថ្វាយភ្លេង កិច្ចទម្លាក់បង្គង កិច្ចថ្វាយកំពង់ និងកិច្ចបញ្ចុះទូកជាដើម។ នៅក្នុងអត្តបទនេះ យើងលើកយក **"កិច្ចបញ្ចុះទូកឬទម្លាក់បង្គង"** របស់អ្នកភូមិកំពង់ឈើទាល ខេត្តកំពង់ធំ មកបង្ហាញដោយសង្ខេប។ តើកិច្ចបញ្ចុះទូកឬទម្លាក់បង្គងរបស់អ្នកភូមិកំពង់ឈើទាល មានដំណើរការប្រព្រឹត្តទៅយ៉ាងដូចម្តេចខ្លះ?

ភូមិកំពង់ឈើទាល ជាភូមិដែលស្ថិតនៅជាប់ដងស្ទឹងសែន ក្នុងភូមិសាស្ត្រឃុំសំបូរណ៍ និងឃុំតាំងក្រសៅ ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ។ ជាទូទៅ នៅចន្លោះខែតុលា ដល់ខែវិច្ឆិកា អ្នកស្រុកនៅតាមដងស្ទឹងសែន រួមទាំងអ្នកភូមិកំពង់ឈើទាលផងតែងតែប្រារព្ធពិធីបុណ្យអុំទូកប្រចាំតំបន់ជារៀងរាល់ឆ្នាំ មុននឹងត្រៀមខ្លួនទៅប្រកួតប្រជែងថ្នាក់ខេត្ត និងថ្នាក់ជាតិ (រូបលេខ១)។ តាមទម្លាប់មុនការប្រកួត ទូកស្ទើរតែទាំងអស់ត្រូវចុះទឹក ដើម្បីឱ្យចំណុះ(អ្នកអុំ)ហាត់សម និងហ្វឹកហ្វឺនកម្លាំង។ ម្ល៉ោះហើយ ទើបមានតំបន់ខ្លះប្រារព្ធកិច្ចពិធីផ្សេងៗមុនពេលទូកចុះទឹក។ ជាក់ស្តែង ទូកងនៅភូមិកំពង់ឈើទាល មានឈ្មោះថា **"ឯកសុវណ្ណច័ន្ទមូលី"** ស្ថិតនៅវត្តច័ន្ទមូលី នៅតែរក្សាទំនៀមទម្លាប់ **"កិច្ចបញ្ចុះទូក"** មុននឹងលើកទូកងចុះទឹក។ ជាធម្មតាឈ្មោះទូកតែងបង្ហាញពីអត្តសញ្ញាណតំបន់ ដូចជាឈ្មោះភូមិ វត្ត ឬសត្វជាដើម ហើយនាសម័យក្រោយមក ក៏មានការដាក់បន្ថែមឈ្មោះអ្នកឧបត្ថម្ភធំផងដែរ។ ចំពោះទូក **"ឯកសុវណ្ណច័ន្ទមូលី"** ក៏មិនខុសគ្នាដែរ ពោលគឺពាក្យ **"ឯក"** គឺជាឈ្មោះអ្នកតាមួយអង្គដែលថែរក្សាការពារទូកក្នុងវត្តនេះជាយូរយារមកហើយ។ រីឯពាក្យ **"ច័ន្ទមូលី"** គឺសំដៅលើឈ្មោះវត្តតែម្តង។ មុនពេលមានទូកងនេះ វត្តច័ន្ទមូលី ធ្លាប់មានទូកងឈ្មោះ **"បង្គងផ្ទាត់ចង្កាន់ហុយ"** ធ្វើដោយក្រុមលោកតាប្រុក មកពីភូមិតាំងក្រង ឃុំតាំងក្រសៅ ស្រុកប្រាសាទ

អត្តបទដោយ៖ ស្រី សមប៊ុនណារ៉ុង

សំបូរ ខេត្តកំពង់ធំ។ ទោះតួទូកពុំសេសសល់ តែក្បែកទូកមួយគូត្រូវបានគេរក្សាទុកយ៉ាងល្អ និង យកមកបំពាក់ឱ្យទូកក្នុងវត្តជាបន្តបន្ទាប់ (រូបលេខ៣)។ លុះដល់ឆ្នាំ១៩៩១ ទូកឯឈ្មោះ **"ឯកសុវណ្ណចន្ទមូលី"** បានបង្កើតឡើយ ហើយរហូតដល់ឆ្នាំ២០០៣ គេធ្វើទូកថ្មីមួយទៀតដោយដាក់ឈ្មោះដដែលនិងមានចំណុះ៥៧នាក់។ រីឯទូកចាស់គេបានប្តូរឈ្មោះទៅជា **"ឯកសុវណ្ណចន្ទបុប្ផា"** សម្រាប់ឱ្យនារីអុំវិញម្តង (រូបលេខ៦)។ ទូកទាំងពីរនេះ គឺជាស្នាដៃរបស់លោកតា **ម៉ែន ទុន** ដែលជាជាងទូកដ៏ចំណាន និងមានកិត្តិនាមល្បីល្បាញក្នុងវិស័យទូកង ព្រោះទូកដែលលោកធ្វើ តែងតែមានល្បឿនលឿន និងល្បីល្បាញធាប់រហ័ស (រូបលេខ៥)។

មុនពេលចាប់ផ្តើមកិច្ចបញ្ចុះទូកឬទម្លាក់បង្គន់ ចំណុះទូកទាំងអស់ រួមទាំងចាស់ទុំបានមកជួបជុំគ្នានៅក្នុងរោងទូក។ ព្រមជាមួយគ្នានេះ ក៏មានវត្តមានរូបស្នងម្នាក់មកចូលរួមកិច្ច ដើម្បីឱ្យអ្នកតាដែលថែរក្សាទូកចូលមកសណ្ឋិត តាមរយៈការប្រគុំភ្លេងអារក្សធង (រូបលេខ៦-៧)។ នៅក្នុងពេលនោះ រូបស្នងដែលមានអមនុស្សកំពុងចូលសណ្ឋិត បានធ្វើត្រាប់តាមកាយវិការអ្នកអុំទូកង និងបានចងខ្សែអំបោះដល់ទូកង ច្រវ និងចំណុះទូក (រូបលេខ៨-៩)។ លុះពេលអ្នកតាពាក់មន្ត្រសប្បាយចិត្តហើយក៏លាចេញពីក្នុងខ្លួនរូបស្នង ដោយបានផ្តាំផ្ញើថា លោកនឹងជួយបីបាច់ថែរក្សាកម្លាំងចំណុះទូកឱ្យមានសុខសុវត្ថិភាព និងទទួលបានជ័យជម្នះក្នុងការប្រកួត។ បន្ទាប់មក ចំណុះទូកទាំងអស់បាននាំគ្នាលើកទូកដើម្បីយកទៅកំពង់ ពេលគឺចុះទឹក។ មុននឹងលើកចេញ គេឃើញមានលោកតាចំណាស់ម្នាក់ដែលមានតួនាទីជាអ្នកបញ្ជានៅលើក្បាលទូកបានស្រែកឡើងថា **"ទូកជាបល្ល័ង្ក ស្រឡោជារនាំង ចង្វារជាព្រះខ័នជ័យ!"** (រូបលេខ១០)។ ស្រឡោនៅត្រង់នេះ សំដៅដល់ក្តារសន្ទះសុះឬគ្របត្រង់ច្រក-កទូកខាងក្បាលឬខាងកន្ទៃ ដែលជាទូទៅមានពាក្យពេញហៅថា "ស្រឡោកោ"។ ការស្រែកបែបនេះ គឺគេយកលំនាំលោកតា **ម៉ែន ទុន** ដែលជាជាងធ្វើទូកផ្ទាល់។ ហេតុដូច្នេះពាល់ទូករបស់គាត់ធ្វើ គឺភាគច្រើនតែងមានទម្រង់ស្រែកបែបនេះដូចៗគ្នា។ លុះស្រែកចប់ គេក៏នាំគ្នាតម្រង់ជួរដង្កៃទូកចេញពីរោង សំដៅទៅកាន់មាត់កំពង់ដើម្បីទម្លាក់ទូកចុះទឹក (រូបលេខ១១)។ ក្នុងអំឡុងពេលហាត់សម អ្នកសំឡេងខ្លាំងម្នាក់ស្រែកដាស់កម្លាំងដល់ចំណុះទូក និងថែមទាំងមានអ្នកបន្ទរ ដូចខាងក្រោម (រូបលេខ១២)៖

- *អើយឯក! អើយសៅរ៍! នាងពៅព្រៃគោ៎ះ (ហែអើ៎!)*
- *អើយឯក! អើយម៉ោ! នាងពៅព្រៃគុក (ហែអើ៎!)*
- *អើយឯក! អើយសៅរ៍! នាងពៅព្រៃគោ៎ះ (ហែអើ៎!)*
- *តាដុំដែក! ហែកយាយម៉ោ! នាងពៅព្រៃគុក (ហែអើ៎!)*

អត្ថបទដោយ៖ ស្រី សមប៊ុនណារ៉ុង

- *លោកតាទាំងអស់ ជួយទូកឱ្យឈ្នះ! (ហែអើ!)*

ពាក្យស្រែកប្រចាំទូកនេះកើតឡើងជាយូរមកហើយ ហើយអ្នកភូមិដែលជាចំណុះទូកបានស្រែកតៗគ្នាពីមួយជំនាន់ទៅមួយជំនាន់។ គេជឿថាពាក្យស្រែកដែលបានស្រែកនេះ គឺអ្នកតាជាអ្នកផ្តល់ឱ្យ ដើម្បីជួយដាស់កម្លាំងស្មារតី និងបន្ថែមថាមពលដល់ចំណុះទូកឱ្យមានកម្លាំងខ្លាំងក្លាជាងមុន ទើបបានជាពាក្យស្រែកនេះនៅតែបន្តឥតដាច់មកដល់សព្វថ្ងៃ។

*សរុបជារួមមក កិច្ចបញ្ចុះទូកឬទម្លាក់បង្គន់របស់អ្នកភូមិកំពង់ឈើទាល ខេត្តកំពង់ធំ មិនត្រឹមតែជាទំនៀមទម្លាប់ប្រពៃណីមុនពេលយកទូកចុះទឹកប៉ុណ្ណោះទេ តែវាបានបង្ហាញអំពីស្មារតីសាមគ្គីភាពក្នុងសហគមន៍ និងការថែរក្សាមត៌កវប្បធម៌អរូបីពីមួយជំនាន់ទៅមួយជំនាន់។ តាមរយៈកិច្ចសែនព្រេន ការចូលរួបស្នងរបស់អ្នកតា ព្រមទាំងពាក្យស្រែក និងក្បួនខ្នាតដែលបន្សល់ទុកដោយជាងទូកជើងចាស់ទាំងអស់នេះ បានក្លាយជាមូលដ្ឋានជំនឿដ៏រឹងមាំក្នុងការជួយដាស់ស្មារតី បង្កើនថាមពល និងជាទីពំនាក់ផ្លូវចិត្តដ៏សំខាន់សម្រាប់ចំណុះទូក "**ឯកសុវណ្ណចន្ទមួលី**" ក្នុងការចោះជំហានចូលរួមប្រកួតប្រជែងដោយភាពអង់អាច និងចូលរួមថែរក្សាមត៌កវប្បធម៌ខ្មែរឱ្យគង់វង្សតទៅមុខទៀត។*

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ ស្រី សមប៊ុនណារ៉ុង

បញ្ជីឯកសារពិគ្រោះ

ធុល សុភ័ណ្ឌ, ២០០៦, *ទូក*, សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ នៅមហាវិទ្យាល័យបុរាណវិទ្យា ជំនាន់ទី១៤, ភ្នំពេញ។

មាស សុភាព ២០២១, "ពិធីបុណ្យអុំទូក", អត្ថបទផ្សាយអនឡាញនៅក្នុង *AMS Khmer Civilization*, នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២១ តាមរយៈតំណភ្ជាប់
https://khmercivilization.ams.com.kh/detail/1301

យ៉ា ដា, ១៩៩៥, *ទូកប្រណាំងវែងខ្មែរ*, សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ នៅមហាវិទ្យាល័យបុរាណវិទ្យា ជំនាន់ទី៣, ភ្នំពេញ។

ហួន សាវង ២០២២, "ទូកប្រណាំង និងទំនៀមអ្នកស្រុក (ភាគ១-២)", អត្ថបទផ្សាយអនឡាញនៅក្នុង *AMS Khmer Civilization*, នៅខែវិច្ឆិកា ឆ្នាំ២០២១ តាមរយៈតំណភ្ជាប់
https://khmercivilization.ams.com.kh/detail/25010
https://khmercivilization.ams.com.kh/detail/24926

ហួន សាវង, ២០២៥, "សិល្បៈ និងជំនឿប្រតិបត្តិចំពោះក្បាលទូកង", អត្ថបទផ្សាយអនឡាញនៅក្នុង *AMS Khmer Civilization*, នៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២១ តាមរយៈតំណភ្ជាប់
https://khmercivilization.ams.com.kh/detail/33262



រូបលេខ១៖ ពិធីអុំទូកប្រចាំតំបន់ នៅភូមិកំពង់ឈើទាល ស្រុកជ្រាសាទសំបូរ ខេត្តកំពង់ធំ



រូបលេខ២៖ កម្លាំងសាមគ្គីរបស់អ្នកភូមិកំពង់ឈើទាល

អត្ថបទដោយ៖ ស្រី សមប៊ុនណារ៉ុង



រូបលេខ៣៖ ក្បែកទូក ដែលសល់ពីបុរាណ



រូបលេខ៤៖ ទូកចាស់ ប្តូរឈ្មោះទៅជាឯកសុវណ្ណចន្ទបុប្ផា

អត្ថបទដោយ៖ ស្រី សមប៊ុនណារ៉ុង



រូបលេខ៥៖ លោកតា ម៉ែន ទន់ ជាជាងទូកដ៏ចំណាន



រូបលេខ៦៖ អ្នកចូលរួមក្នុងកិច្ចបញ្ចុះទូកឬទម្លាក់បង្គន់នៅភូមិកំពង់ឈើទាល

អត្ថបទដោយ៖ ស្រី សមប៊ុនណារ៉ុង



រូបលេខ៧៖ ការប្រគុំភ្លេងអារក្សក្នុងកិច្ចបញ្ចុះទូកឬទម្លាក់បង្គន់នៅភូមិកំពង់ឈើទាល



រូបលេខ៨៖ រូបស្នងក្នុងអំឡុងអ្នកតាកំពុងចូលសណ្ឋិត ធ្វើត្រាប់សកម្មភាពអុំទូក

អត្ថបទដោយ៖ ស្រី សមប៊ុនណារ៉ុង



រូបលេខ៩៖ អ្នកតាកូចអំបោះដល់អ្នកអុំទូក



រូបលេខ១០៖ អ្នកបញ្ជាក្បាលទូកស្រែកពាក្យស្នោកថា

"ទូកជាបល្ល័ង្ក ស្រេឡោជារនាំង ចង្វាជាព្រះខ័នជ័យ"

អត្ថបទដោយ៖ ស្រី សមប៊ុនណារ៉ុង



រូបលេខ១១៖ ដង្ហែទូកថ្វាយកំពង់ ឬចុះទឹក



រូបលេខ១២៖ ការហាត់សមកម្លាំង និងស្រែកពាក្យស្លោកប្រចាំទូកមួយបែប
ដើម្បីហៅរកអ្នករក្សាទូក មកជួយជាស់ស្មារតី និងផ្តល់កម្លាំងដល់ចំណុះទូក

អត្ថបទដោយ៖ ស្រី សមប៊ុនណារ៉ុង